Khmer / ខ្មែរ

# Office of the WorkCover OMBUDSMAN South Australia

Office of the WorkCover Ombudsman (ការិយាល័យមន្ត្រីផ្លូវការស៊ើបអង្កេត និងទទួលពាក្យបណ្តឹងពលរដ្ឋរបស់ WorkCover)* ផ្តល់ឱវាទ និងជំនួយដោយឥតគិតថ្លៃដល់អ្នកធ្វើការដែលមានរបួស និងនិយោជកដែលមានការប្តឹងតវ៉ាអំពីវិធីដែលកិច្ចបំរើនានាដែលបានចាត់ចែងនៅក្នុងគម្រោងការ WorkCover (WorkCover Scheme)។

នេះគឺជាការិយាល័យឯករាជ្យ ដែលតាមដានការប្តឹងតវ៉ាអំពីការអនុវត្តន៍របស់គម្រោងការ WorkCover ហើយរាយការណ៍អំពីបញ្ហាទាំងឡាយទាក់ទិនជាមួយគ្រោងការទៅរដ្ឋមន្ត្រីទំនាក់ទំនងឧស្សាហកម្ម។

លោកអ្នកអាចទាក់ទងជាមួយការិយាល័យមន្ត្រីផ្លូវការស៊ើបអង្កេត និងទទួលពាក្យបណ្តឹងពលរដ្ឋរបស់ WorkCover តាមរយៈ

| | |
|---|---|
| **ទូរស័ព្ទ** | 1800 195 202 **(ទូរស័ព្ទឥតគិតថ្លៃ)** |
| **ទូរសារ** | (08) 8204 2169 |
| **អ៊ីម៉ែល** | owo@saugov.sa.gov.au |
| **អាសយដ្ឋានតាមផងផ្លូវ** | Level 6, Chesser House<br>91-97 Grenfell St ADELAIDE SA |
| **អាសយដ្ឋានផ្ញើតាមប៉ុស្តិ៍** | GPO Box 2343 ADELAIDE SA 5001 |
| **DX** | DX 56201 ADELAIDE |

ប្រសិនបើលោកអ្នកចង់និយាយទៅកាន់បុគ្គលិកផ្ទាល់ សូមធ្វើការណាត់ជួបដោយទូរស័ព្ទទៅការិយាល័យមន្ត្រីផ្លូវការស៊ើបអង្កេត និងទទួលពាក្យបណ្តឹងពលរដ្ឋរបស់ WorkCover ជាមុន។

## មុខងាររបស់មន្ត្រីផ្លូវការស៊ើបអង្កេត និងទទួលពាក្យបណ្តឹងពលរដ្ឋរបស់ WorkCover គឺដើម្បី:

- ទទួល តាមដាន ហើយស្វែងរកដំណោះស្រាយការប្តឹងតវ៉ាពីនិយោជិត និយោជក និងគូភាគីដែលជាប់ទាក់ទិនឯទៀតអំពីវិធីដែលកិច្ចបំរើនានាដែលបានចាត់ចែងនៅក្នុងគម្រោងការ WorkCover។
- តាមដានបញ្ហាទាំងឡាយដែលទាក់ទិនជាមួយនឹងការកែលំអកាយសម្បទាឲ្យល្អដូចដើមវិញ និងការវិលត្រឡប់ទៅធ្វើការវិញនៃអ្នកធ្វើការដែលមានរបួស ពោលគឺកាតព្វកិច្ចរបស់និយោជក ការចាត់ចែងនៃកិច្ចបំរើកែលំអកាយសម្បទាឲ្យល្អដូចដើមវិញ ការបំពាននៃភាពសម្ងាត់ផ្ទាល់ខ្លួន ការផ្តល់នូវព័ត៌មាន។ល។
- ពិនិត្យមើលឡើងវិញលើសេចក្តីសំរេច ដើម្បីបញ្ឈប់ការបើកប្រាក់ប្រចាំសប្តាហ៍ដល់អ្នកធ្វើការដែលមានរបួស។
- សម្គាល់ឲ្យបានដឹងពីបញ្ហាដែលកើតមានពីការអនុវត្តន៍ ឬការចាត់ចែងនៃច្បាប់ *Workers Rehabilitation and Compensation Act 1986*។ ច្បាប់សងជម្ងឺចិត្ត និងការកែលំអកាយសម្បទាឲ្យល្អដូចដើម វិញដល់អ្នកធ្វើការ ឆ្នាំ១៩៨៦)
- លើកទឹកចិត្ត ហើយជួយ WorkCoverSA និងនិយោជកដើម្បីបង្កើតដំណើរការចាត់ចែងរបស់ខ្លួនផ្ទាល់ដើម្បីដោះស្រាយការប្តឹងតវ៉ា។

*កំណត់ចំណាំ: ប្រសិនបើលោកអ្នកមានការប្តឹងតវ៉ាណាមួយ ជាទូទៅ យើងស្នើសុំឲ្យលោកអ្នកសាកល្បងដោះស្រាយរឿងនោះជាមួយជន ឬអង្គការដែលទាក់ទិនជាមុនសិន មុននឹងបញ្ជូនការប្តឹងតវ៉ាទៅការិយាល័យមន្ត្រីផ្លូវការស៊ើបអង្កេត និងទទួលពាក្យបណ្តឹងពលរដ្ឋរបស់ WorkCover។*

ប្រសិនបើលោកអ្នកប្រាថ្នាចង់និយាយទៅកាន់ការិយាល័យមន្ត្រីផ្លូវការស៊ើបអង្កេត និងទទួលពាក្យបណ្តឹងពលរដ្ឋរបស់ WorkCover នៅក្នុងភាសាដែលលោកអ្នកចូលចិត្ត សូមទូរស័ព្ទមណ្ឌលបកប្រែភាសានិយាយ និងភាសាសរសេរលេខ (08) 8226 1990 រួចស្នើសុំអ្នកបកប្រែភាសាឲ្យទាក់ទងជាមួយការិយាល័យមន្ត្រីផ្លូវការស៊ើបអង្កេត និងទទួលពាក្យបណ្តឹងពលរដ្ឋតាមទូរស័ព្ទលេខ 1800 195 202 (ទូរស័ព្ទឥតគិតថ្លៃ)។ កិច្ចបំរើបកប្រែភាសានេះផ្តល់ជូនលោកអ្នកដោយឥតគិតថ្លៃ។

** មន្ត្រីផ្លូវការស៊ើបអង្កេត និងទទួលពាក្យបណ្តឹងរបស់ពលរដ្ឋ គឺជាជនម្នាក់ដែលបានតែងតាំងដើម្បីតាមដានរឿងប្តឹងតវ៉ា។*